បណ្ណាល័យ
គ.ជ.អ.ប

# វិមជ្ឈការ និង កំណែទំរង់ក្រុមប្រឹក្សាឃុំៈ

## ឱកាសជាបន្ទាន់ សំរាប់ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

# Decentralisation and Commune Council Reforms: Immediate Opportunities for Cambodian NGOs

Mr. Robin Biddulph

Oxfam GB អុកស្វាម អង់គ្លេស
Phnom Penh ភ្នំពេញ
December 2000 ខែ ធ្នូ ឆ្នាំ ២០០០

352.283
BiD
sh: D&D.

NCDD Library
001963

## សង្ខេប


គោលបំណងអត្ថបទដោយសង្ខេបនេះ គឺដើម្បីជួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងការគិតគូរអំពីអ្វីដែល ពួកគេអាចធ្វើឥឡូវនេះ ដើម្បីត្រៀមខ្លួនប្រឈមមុខនឹងការផ្លាស់ប្តូរនានា ពាក់ពន្ធ័ដល់ការធ្វើវិមជ្ឈការ និងកំនែទំរង់ថ្នាក់ឃុំ ។ វាគឺជាការសរសេរជាបឋម សំរាប់អង្គការអភិវឌ្ឍន៏ មិនមែនរដ្ឋាភិបាលក្នុងស្រុក ធ្វើការងារនៅថ្នាក់មូលដ្ឋានក៏ដូចជា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានបំណងបញ្ចេញឥទ្ធិពលកែលំអរទៅលើ គោលនយោបាយថ្នាក់ជាតិរបស់រដ្ឋាភិបាល ។

ច្បាប់បោះឆ្នោតឃុំ និងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ គឺអាស្រ័យទៅលើអ្វីដែលបានពិភាក្សាដោយសភាជាតិ ។ពង្រាងទាំងនេះ ប្រមើលមើលទៅដល់ការបង្កើតក្រុមប្រឹក្សាឃុំ នៅគ្រប់ឃុំទាំងអស់ទូទាំងប្រទេស ។ ឯកសារផ្សេងៗទៀតរបស់រដ្ឋាភិបាលបានកំណត់ក្រុមប្រឹក្សាឃុំជា "ភ្នាក់ងារថ្នាក់ក្រោមបំផុត នៃការអភិវឌ្ឍន៏មូលដ្ឋាន" ។

កំនែទំរង់ទាំងនេះ នឹងប្រែប្រួលដល់បរិយាកាសសំរាប់ការអភិវឌ្ឍន៏មូលដ្ឋាននៅប្រទេសកម្ពុជា ។ វាមិនទាន់ច្បាស់នៅឡើយថាការប្រែប្រួលទាំងនោះនឹងមានផលប៉ះពាល់ដល់អង្គការមិនមែនរដ្ឋាភិបាលយ៉ាងដូចម្តេច ។ វាក៏មិនច្បាស់ផងដែរថាតើពេលនោះនឹងមានឱកាសអ្វីសំរាប់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបញ្ចេញអនុភាពទៅលើកាប្រែប្រួលនោះ ។ ឯកសារនេះសូមផ្តល់ នូវគំនិតយោបល់ ដល់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីសំរបខ្លួនប្រកបដោយជោគជ័យ និងដើម្បីឆក់យកឱកាសនោះផងដែរក្នុងការបញ្ចេញអានុភាពទៅ លើរូបមន្តនៃគោលនយោបាយវិមជ្ឈការ វានឹងជាការចាំបាច់សំរាប់ពួកគេដើម្បី ត្រៀមគោលគំនិត និងយុទ្ធសាស្ត្ររបស់ខ្លួន ដូច្នេះពួកគេអាចមានប្រតិកម្ម តបតនៅពេលឱកាសមកដល់ ។

អង្គការមិនមែនរដ្ឋាភិបាល មួយចំនួនបានបង្កើតរួចជាស្រេច នូវសម្ព័ន្ធ និងបណ្តាញការងារ ដើម្បីត្រៀមខ្លួនជាមុន និងពង្រឹងអនុភាពទៅលើការកែទំរង់ថ្នាក់ឃុំ ។ ជាបន្ថែមទៅលើការចូលរួមនៅក្នុងបណ្តាញការងារ នៃអង្គការមិនមែនរដ្ឋាភិបាល នៅមានបញ្ហាផ្សេងៗទៀត ដែលអង្គការមិនមែនរដ្ឋាភិបាល អាចធ្វើឥឡូវនេះ ក្នុងការត្រៀមខ្លួនជាមុន ចំពោះមុខការបង្កើតក្រុមប្រឹក្សាឃុំ ។ អង្គការមិនមែនរដ្ឋាភិបាល មួយចំនួន នឹងមានការគិតគូរយ៉ាងជ្រៅជ្រះហើយជាស្រេចអំពីបញ្ហាទាំងនេះ ហើយឯកសារនេះប្រហែល នឹងមិនបានផ្តល់អ្វីច្រើនទេទៅដល់ពួកគេ។ សំរាប់អ្នកផ្សេងៗទៀតដែលទើបនឹងចាប់ផ្តើមគិតអំពី ការគ្រប់គ្រងថ្នាក់ឃុំ ឯកសារនេះមានសង្ឃឹមថា គោលគំនិត និងមតិយោបល់ ប្រហែលជាមានប្រយោជន៏ ។ ជាសង្ខេបមតិយោបល់គឺ:

**សំរាប់ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការអភិវឌ្ឍន៍នៅមូលដ្ឋាន:**

- ពង្រឹងចំនងមិត្តភាព ជាមួយអ្នកនយោបាយ និងមន្ត្រីថ្នាក់ឃុំបច្ចុប្បន្ន។
- ចាប់ផ្តើមបង្កើតគំនិតអំពីការទទួលខុសត្រូវណា ដែលឃុំអាចធ្វើបាន និងគួរតែមាន។
- ស្វែងយល់ពីតួនាទី នៃកម្មវិធី សីលា នៅក្នុងខេត្តដែលមាន អង្គការមិនមែនរដ្ឋាភិបាលធ្វើការ ទាំងនៅថ្នាក់ កំនែទំរង់វិមជ្ឈការថ្នាក់ជាតិ ។

**សំរាប់ អង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងរួមចំនែកក្នុងការបង្កើតគោលនយោបាយ:**

- នាំមកនូវព័តមាន និងជំនាញ ដែលអ្នកបង្កើតគោលនយោបាយរបស់រដ្ឋាភិបាល នឹងមើលឃើញ ថាមានប្រយោជន៍។
- ចាប់ផ្តើមបង្កើតនូវទស្សនៈមួយ នៃតួនាទីថ្នាក់ឃុំនៅក្នុងការគ្រប់គ្រងនៅកម្ពុជា
- បង្កើតការយោគយល់គ្នាយ៉ាងល្អជាមួយអ្នក នៅក្នុងជួររដ្ឋាភិបាល ដែលគាំទ្រនូវឧត្តមគតិណាមួយ ចំពោះ រឿង កំនែទំរង់ថ្នាក់ឃុំ។

ឯកសារសន្និដ្ឋានដោយកត់សំគាល់ថា រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល មានគោលបំណងរួម ដូចគ្នាជាច្រើនចំពោះរឿងវិមជ្ឈការ និងកំនែទំរង់ថ្នាក់ឃុំ ។ហេតុដូច្នេះវាមានសង្ឃឹមថា វិធីសាស្ត្រកសាង ភាពស្រុះស្រួលដោយគ្មានការប្រឈមមុខដាក់គ្នាបែបនេះយូរទៅបានក្លាយទៅជាការជោគជ័យ នៅក្នុងការតស៊ូមតិអោយមានការកែទំរង់ដីធ្លីនៅកម្ពុជា ហើយប្រហែលជាអាចប្រើប្រាស់បានផងដែរទាក់ទងក្នុងការ តស៊ូមតិអោយមានការកែទំរង់ថ្នាក់ឃុំ ។កិច្ចឃោសនាប្រហែលនឹងផ្តល់ការផ្តោតជាពិសេសទៅលើ " ការសហការគ្នានៃ រដ្ឋការមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន ដើម្បីសំរេចបាននូវ អភិបាលកិច្ចល្អ" និង " ធ្វើអោយប្រាកដថាការអភិវឌ្ឍន៍ អនុលោមភាគច្រើនទៅតាមនយោបាយមូលដ្ឋាន"

មាតិការ

# ទិមជ្ឈការ និង កំណែទំរង់គ្រួមប្រឹក្សាឃុំៈ ឱកាសជាបន្ទាន់ សំរាប់ អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក


**សង្ខេប** ....................................................................................................................................... ១-២

សំរាប់ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការអភិវឌ្ឍន៍នៅមូលដ្ឋានៈ .............................................................. ២

សំរាប់ អង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងរួមចំនែកក្នុងការបង្កើតគោលនយោបាយៈ........................... ២

**ប្រវត្តិ ចំពោះវិមជ្ឈការ និងកំណែទំរង់ថ្នាក់ឃុំនៅកម្ពុជា** ........................................................................... ៥

ផលប្រយោជន៍នៃវិមជ្ឈការ-ផ្នែកទ្រឹស្តី ..................................................................................................... ៥

ច្បាប់បច្ចុប្បន្ន ........................................................................................................................................ ៦

រូបមន្តគោលនយោបាយបច្ចុប្បន្ន ............................................................................................................ ៧

ការឆ្លើយតបរបស់អង្គការមិនមែនរដ្ឋាភិបាលនាបច្ចុប្បន្ន ............................................................................ ៧

**ហេតុផលសំរាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចាប់ផ្តើមសកម្មភាពឥឡូវនេះ** ......................................... ៩

ឱកាស ..................................................................................................................................................... ៩

ឧបសគ្គ .................................................................................................................................................. ១០

**អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការអភិវឌ្ឍន៍នៅមូលដ្ឋាន និងកំណែទំរង់ថ្នាក់ឃុំ**........... ១១

ពង្រឹងទំនាក់ទំនងជាមួយមន្ត្រីថ្នាក់ឃុំ និងអ្នកនយោបាយ .......................................................................... ១១

បង្កើតទស្សនៈមួយ នៃតួនាទីរបស់ថ្នាក់ឃុំ ................................................................................................. ១៣

រៀនសូត្រអំពីកម្មវិធីសីលា ....................................................................................................................... ១៥

**អង្គការជាតិមិនមែនរដ្ឋាភិបាល និងការចូលរួមក្នុងការបង្កើតគោលនយោបាយវិមជ្ឈការ** ....២០

នាំមកនូវពិតមានដែលពាក់ព័ន្ធ និងជំនាញ ................................................................................................ ២១

បង្កើតទស្សនៈមួយ នៃតួនាទីរបស់ថ្នាក់ឃុំ ................................................................................................. ២២

ស្វែងយល់ពីរបៀប និងគំរិតនៃការគាំទ្រដល់ការកែទំរង់ថ្នាក់ឃុំ ................................................................... ២២

**ការជាប់ទាក់ទងដល់អង្គការម្ចាស់មូលនិធិ** ............................................................................................. ២៣

ការប្រមើលមើលជាមុននូវការប្រែប្រួល ...................................................................................................... ២៣

គាំទ្រដល់បណ្តាញការងារ និងការកសាងភាពស្រុះស្រួលគ្នា ........................................................................ ២៤

ជ្រើសរើសអ្នកជំនាញដែលពាក់ព័ន្ធ .......................................................................................................... ២៤

**សេចក្តីសន្និដ្ឋាន** ............................................................................................................ ២៤

**ឯកសារយោង** ............................................................................................................ ២៦

**ឧបសម្ពន្ធ: គំរោងនៃដំណើរការធ្វើផែនការមូលដ្ឋានរបស់កម្មវិធីសីលា** ................................ ២៨

ដំណាក់កាលទី១: ការតំរង់ទិសនៃការធ្វើផែនការមូលដ្ឋាន (LPP Orientation)

ដំណាក់កាលទី២: កំណត់ភូមិអាទិភាពសំរាប់រយៈពេល ៣ឆ្នាំ

ដំណាក់កាលទី៣: បង្កើតផែនការអភិវឌ្ឍន៍ឃុំ (CDP)

ដំណាក់កាលទី៤: សិក្ខាសាលាអំពីការធ្វើសមាហរណកម្ម នៅថ្នាក់ស្រុក

ដំណាក់កាលទី៥: ការបង្កើតឡើងនូវគំរោងផែនការវិនិយោគនៅក្នុងឃុំ (CIP)

ដំណាក់កាលទី៦: ការរៀបចំគំរោងសំណើរ

ដំណាក់កាលទី៧: ការវាយតំលៃគំរោង

ដំណាក់កាលទី៨: ការរៀបចំកិច្ចព្រមព្រៀងគំរោង និងដាក់អោយដេញថ្លៃ

ដំណាក់កាលទី៩: ការឯកភាពលើកិច្ចព្រមព្រៀងគំរោង

ដំណាក់កាលទី១០:ការអនុវត្តគំរោង

ដំណាក់កាលទី១១:សិក្ខាសាលាធ្វើការឆ្លុះបញ្ចាំងឡើងវិញរបស់គណៈកម្មការអភិវឌ្ឍន៍ឃុំ

## ប្រវត្តិ ចំពោះវិមជ្ឈការ និងកំណែទំរង់ថ្នាក់ឃុំនៅកម្ពុជា

### ផលប្រយោជន៍នៃវិមជ្ឈការ[1] ផ្នែកទ្រឹស្តី

ទ្រឹស្តីមូលដ្ឋានមួយនៃវិមជ្ឈការត្រូវបានគេហៅថា ជាទ្រឹស្តីបន្ទាប់បន្សំ។ ផ្អែកទៅតាមគំនិតនេះ មុខងារ មួយចំនួនរបស់ រដ្ឋាភិបាលគួរតែត្រូវបានផ្ទេរទៅដល់ថ្នាក់ដែលអាចធ្វើបាននៅក្រោមបំផុត លុះត្រាតែមានហេតុផលមួយយ៉ាងល្អបំផុតថាហេតុអ្វី ទើបវាគួរតែត្រូវបានធ្វើដោយថ្នាក់ខាងលើរបស់រដ្ឋាភិបាល ។

គុណសម្បត្តិនៃការផ្តល់ការទទួលខុសត្រូវច្រើនថែមទៀតដល់ថ្នាក់ក្រោម នៃរដ្ឋាភិបាលគឺថាចំណុចនេះធ្វើអោយរដ្ឋាភិបាល " កាន់តែខិតទៅជិតប្រជាជន" ។ នេះគឺមានសង្ឃឹមថា នាំទៅរកការអភិវឌ្ឍន៍ដែល កាន់តែមានប្រសិទ្ធិឡើង ពីព្រោះតែគុណសម្បត្តិដូចខាងក្រោមៈ

- រដ្ឋការមូលដ្ឋាន នឹងដឹងនូវស្ថានភាពមូលដ្ឋានប្រសើរជាង ហើយហេតុដូច្នេះនឹងអាចធ្វើសេចក្តី សំរេចចិត្តដោយផ្អែកលើអ្វីដែលជាតម្រូវការរបស់ប្រជាជនមូលដ្ឋាន ។ រដ្ឋការថ្នាក់ខេត្ត ឬថ្នាក់ជាតិអាចមិនដឹង ស្ថានភាពមូលដ្ឋានច្បាស់លាស់ប៉ុន្មានទេ។
- រដ្ឋការមូលដ្ឋាន នឹងបានយល់ដឹងយ៉ាងប្រសើរតាមរយៈប្រជាជន ដូច្នេះហើយប្រជាជននឹងអាចក្តាប់បាននូវការទទួលខុសត្រូវរបស់រដ្ឋការនោះ។ ជាឧទាហរណ៍ ប្រសិនបើអ្នកធ្វើការមកពីខេត្ត ឬមកពី ភ្នំពេញចូលមកសាងសង់សាលាមួយហើយប្រើប្រាស់ឈើមិនល្អ ប្រជាជនអាចជួបប្រទះការពិបាក ក្នុងការទំនាក់ទំនងអ្នកទទួលខុសត្រូវ។ បើសិនអ្នធ្វើការទាំងនោះត្រូវបានបញ្ជូនដោយឃុំ វាងាយស្រួលសំរាប់ប្រជាជន ទាក់ទងជាមួយឃុំដើម្បីដោះស្រាយបញ្ហា។
- រដ្ឋការមូលដ្ឋានមានហេតុផលច្រើន ដើម្បីបំពេញការងារប្រកបដោយគុណភាពល្អ ។ កូនរបស់មន្ត្រី និងអ្នកនយោបាយមូលដ្ឋាន នឹងត្រូវតែបានទៅសាលារៀនដែលពួកគេសាងសង់។ ម្យ៉ាងវិញទៀត ពេលមានការបោះឆ្នោតពួកគេ ភាគច្រើនទំនងជាត្រូវបានជាប់ឆ្នោត បើសិនជាសាលារៀន ដែលពួកគេបានសង់ឡើងមានគុណភាពល្អ។

ម្យ៉ាងវិញទៀត គុណវិបត្តិដែលចៀសពុំរួច អាចកើនថែមទៀតអាស្រ័យលើវិមជ្ឈការ ឧបមាដូចជា :

- បន្ថយការត្រួតពិនិត្យពី ថ្នាក់កណ្តាល ។ ចំណុចនេះ អាចនាំទៅរកជំលោះ ជាពិសេសនៅក្នុង បណ្តាប្រទេសណាមានជាតិសាសន៍ និងវប្បធម៌ខុសៗ គ្នាលាយឡំក្នុងតំបន់ ។ ការបន្ថយការត្រួតពិនិត្យនេះអាចនាំអោយ

[1] ភាពខុសគ្នាគឺជាធម្មតាបានដកស្រង់ ពីរវាង វិមជ្ឈការ និងសហវិមជ្ឈការ ។ សហវិមជ្ឈការចង់សំដៅទៅលើការ ផ្ទេរអំណាចនៃការទទួលខុសត្រូវនៅ ក្នុងឋានានុក្រមរដ្ឋ ចំណែក ឯវិមជ្ឈការផ្ទេរការទទួលខុសត្រូវដោយឡែកៗ ពីគ្នា ទៅអោយរដ្ឋការមូលដ្ឋានដែលបានជ្រើសតាំងឡើង ។

ចុះខ្សោយនូវសមត្ថភាពនៃរដ្ឋាភិបាលកណ្តាល ក្នុងការអនុវត្តន៍ គោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ច ។

•គោលនយោបាយមូលដ្ឋានគ្មានសមធម៌ ។ ថ្វីបើរដ្ឋការមូលដ្ឋាននៅក្បែរប្រជាជនក៏ដោយ ពួកគេ មិនចាំបាច់ ស្លូតបូតពេកនោះទេ ។ វិមជ្ឈការអាចផ្តល់អំណាចទៅអោយ វរៈជន ឬ បុរសខ្លាំងនៅ មូលដ្ឋាន ។

នៅពេលដែល រដ្ឋាភិបាល និងស្ថាប័នម្ចាស់ជំនួយភាគច្រើន គាំទ្រដល់វិមជ្ឈការ គ្មានភស្តុតាងបញ្ជាក់ថា វិមជ្ឈការ ផ្តល់លទ្ធផលជាស្វ័យប្រវត្តិ ក្នុងការបង្កើនប្រជាធិបតេយ្យ ឬកាត់បន្ថយភាពក្រីក្រនោះទេ ។ ពេលខ្លះ ពេលដែល រដ្ឋាភិបាលកណ្តាលធ្វើវិមជ្ឈការ វាគឺមិនមែនដើម្បីសំរេចបានប្រជាធិបតេយ្យ ឬការ កាត់បន្ថយភាពក្រីក្រឡើយ ប៉ុន្តែសំរាប់ហេតុផលផ្សេងៗទៀតដែលមិនបញ្ចេញ ។ ជូនកាលប្រព័ន្ធ វិមជ្ឈការ ត្រូវការការគាំទ្រច្រើនជាងប្រព័ន្ធ ប្រព័ន្ធវិមជ្ឈការហើយកំនែទំរង់បរាជ័យក៏ព្រោះរដ្ឋាភិបាលកណ្តាលខ្វះសមត្ថភាពគាំទ្រដល់ការផ្លាស់ប្តូរនោះ ។ដូច្នេះ វាមានសារៈ សំខាន់ក្នុងការសិក្សាថាអ្វីទៅ ដែលកំពុងតែ ត្រូវបានធ្វើវិមជ្ឈការ តើកំពុងធ្វើវិមជ្ឈការ ដោយរបៀប ណា ហើយហេតុអ្វីវាកំពុងត្រូវបានធ្វើវិមជ្ឈការ ។

## ច្បាប់ចម្បងៗ

ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ បានចុះហត្ថលេខាដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយគឺអាស្រ័យលើការជជែកវែកញែក ដោយសភាជាតិ ។ ច្បាប់គឺបានកែតំរូវដោយគណៈកម្មការនិតិកម្មរបស់រដ្ឋសភាកាលពីពេលថ្មីៗនេះ ។ច្បាប់នេះ បង្កើតបញ្ញត្តិ សំរាប់ក្រុមប្រឹក្សាឃុំ ដើម្បីបានបោះឆ្នោតដោយប្រជាជនក្នុងឃុំរៀងរាល់ ៥ឆ្នាំ ម្តង ។ ផ្អែកតាម ពង្រាងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ ក្រុមប្រឹក្សាឃុំនិមួយៗនឹងមានពី ៥ ទៅ ១១សមាជិក ( អាស្រ័យទៅតាមទំហំ និងទីតាំងរបស់ឃុំ) ហើយការបោះឆ្នោះសំរាប់ជ្រើសរើសក្រុមប្រឹក្សាឃុំ នឹងត្រូវ ធ្វើឡើងរៀងរាល់ ៥ ឆ្នាំ( មាត្រា ទី១១ និង១២[២] ) ។

យោងតាមពង្រាងច្បាប់ ក្រុមប្រឹក្សាឃុំដែលបានជាប់ឆ្នោត នឹងទទួលខុសត្រូវគ្រប់គ្រងឃុំ ហើយប្រធានក្រុម ប្រឹក្សាឃុំគឺជាមេឃុំ ។ ក្រុមប្រឹក្សាឃុំនឹងមានការទទួលខុសត្រូវផងដែរ ក្នុងការរៀបចំការបោះឆ្នោត គ្រប់ភូមិ ទាំងអស់នៅក្នុងឃុំដើម្បីជ្រើសរើសប្រធានភូមិ ( មាត្រាទី៣០) ។

ក្រុមប្រឹក្សាឃុំនិមួយៗ នឹងត្រូវផ្តល់អោយមានស្មៀនឃុំ ។ស្មៀនឃុំ នឹងត្រូវបានតែងតាំងដោយ រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ[៣] ។មេឃុំនឹងមានសិទ្ធិដកយកប្រាក់ខែឃុំប្រសិនបើក្រុមប្រឹក្សាឃុំគាំទ្រការសំរេចចិត្តនោះ( មាត្រាទី២៨) ។

[២] ច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាលឃុំ (ឃុំ/សង្កាត់) - ឯកសារយោង និងសេចក្តីដកស្រង់ទាក់ទងនឹងការបកប្រែជា ភាសាអង់គ្លេស នៃសេចក្តីពង្រៀងទីពីរដែលបានដាក់ជូនទៅសភាជាតិនាថ្ងៃ ១៣ មិថុនា ឆ្នាំ២០០០ ។ សូមថ្លែងអំណគុណដល់ជំនួយការនៃវេទិកាអង្គការ មិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដែលផ្តល់ឯកសារច្បាប់នោះ១ច្បាប់ ។

[៣] ដូច្នេះស្មៀនឃុំ គឺ ជាមន្ត្រីនៃ សហវិមជ្ឈការ ធ្វើការជាមួយអំណាចវិមជ្ឈការនៃក្រុមប្រឹក្សាឃុំ ។

ផ្អែកតាមពង្រាងច្បាប់ ក្រុមប្រឹក្សាឃុំ នឹងមានការទទួលខុសត្រូវចំពោះមុខ ច្បាប់ និងបទបញ្ជារសេវាសាធារណៈ សុខុមាលភាពសាធារណៈ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ការពារបរិស្ថាន និងធនធានធម្មជាតិហើយជាទូទៅឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន (មាត្រាទី៤៣)។ ក្រុមប្រឹក្សាឃុំនឹងតម្រូវអោយ ធ្វើផែនការអភិវឌ្ឍន៍ឃុំផងដែរនៅឆ្នាំដំបូងនៃតំណែងរបស់ខ្លួន ហើយធ្វើការពិនិត្យផែនការឡើងវិញជា រៀងរាល់ឆ្នាំ (មាត្រាទី៦០-៧២)។ ឃុំនិមួយៗ ក៏នឹងមានមូលនិធិសំរាប់ឃុំផងដែរ (មាត្រាទី៧៧, ៧៨)។

ភាគច្រើននៃសេចក្តីពិស្តារជាគន្លឹះ នៅក្នុងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ គឺអាស្រ័យលើសេចក្តីបំពេញជាក្រោយនៅ ក្នុងអនុក្រិត្យ មិនមែននៅក្នុងច្បាប់ទាំងមូលនោះទេ។

## **ប្រមូលគោលនយោបាយបច្ចុប្បន្ន**

ពេលជាមួយគ្នានេះដែរ បញ្ញាតិជាក់លាក់នោះ គឺកំពុងឆ្លងរដ្ឋាភិបាល ហើយក៏កំពុងធ្វើផែនការបង្កើត គ្រោងការណ៍នយោបាយធំទូលាយមួយសំរាប់វិមជ្ឈការ ។ឯកសារបានរៀបចំសំរាប់កិច្ចប្រជុំក្រុមប្រឹក្សាយោបល់លើកទី៤រវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ បានផ្តល់មតិយោបល់ថា ក្របខ័ណ្ឌគោលនយោបាយសំរាប់វិមជ្ឈការ នឹងត្រូវបានរៀបចំ " កិច្ចពិភាក្សាដោយពេញអង្គជាមួយអ្នកពាក់ព័ន្ធទាំងអស់" ត្រឹមដំណាច់ខែឧសភា ឆ្នាំ២០០១ ហើយច្បាប់បោះឆ្នោត និងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំនោះ នឹងត្រូវបានពិនិត្យឡើងវិញ ទៅលើភាពច្បាស់លាស់ នៃគោលនយោបាយនោះ ក្នុងកំឡុងពេលពី២ ទៅ៣ឆ្នាំបន្ត បន្ទាប់ទៀត[៤]។

## **ការឆ្លើយតបរបស់អង្គការមិនមែនរដ្ឋាភិបាលនាបច្ចុប្បន្ន[៥]**

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន កំពុងធ្វើសកម្មភាព ហើយជាស្រេចជាពិសេស ជាមួយទស្សនៈជំរុញគោលនយោបាយជាតិ ។ ក្រុមការងារស្ត្រីនៃ វេទិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានសហការជាមួយក្រុមត្រួតពិនិត្យការបោះឆ្នោត ក្នុងរឿងបញ្ចុះបញ្ចូលរដ្ឋាភិបាលចំពោះបញ្ញាតិជំរុញការចូលរួមរបស់ស្ត្រី នៅក្នុងក្រុមប្រឹក្សា ឃុំ ។អង្គការចំរើនស្ត្រី ក៏បានរៀបចំសិក្ខាសាលា ដើម្បីជំរុញការចូលរួមរបស់ ស្ត្រីជាបេក្ខជានៅក្នុងការបោះឆ្នោត ។ ក្រុមការងារសង្គមស៊ីវិល នៃវេទិការអង្គកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាបានរៀបចំសិក្ខាសាលា មួយស្តីអំពីវិមជ្ឈការ ដោយមានវាគ្មិន មកពីរាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិ និងអន្តរជាតិ ដែលបានចូលរួមនៅ ក្នុង

---

[៤] គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំនែទំរង់រដ្ឋបាល " កំនែទំរង់រដ្ឋបាល និងអភិបាលកិច្ចល្អ" ខែឧសភា ឆ្នាំ២០០០ (ជាភាសាអង់គ្លេស)។

[៥] ផ្នែកនេះបានដកស្រង់មកពីពត៌មានដែលផ្តល់ដោយ លោក Russell Pterson នៃវេទិការអង្គការមិនមែន រដ្ឋាភិបាល។ កំហុសឆ្គង ឬការដាត់ចោល ជាការទទួខុសត្រូវរបស់អ្នកនិពន្ធ។

ការងារវិមជ្ឈការនៅកម្ពុជា ព្រមទាំងវាគ្មិនអន្តរជាតិ។ វេទិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានបង្កើតក្រុមការងារឱកាសពិសេស(ADHOC)ដែលបានពិគ្រោះយោបល់គ្នាអស់រយៈពេលមួយចំនួននៅឆ្នាំ១៩៩៩-២០០០ ដើម្បីរៀបចំការឆ្លើយតបចំពោះច្បាប់គ្រប់គ្រង រដ្ឋបាលឃុំ ៖ ឯកសារដែលរៀបចំដោយក្រុមការងារនេះ បានដកស្រង់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍ របស់អង្គការមិនមែនរដ្ឋាភិបាលទៅ កាន់កិច្ច ប្រជុំសហគមន៍ម្ចាស់ជំនួយហើយ ការឆ្លើយតបជាសេចក្តីពិស្តារ ថែមទៀតទៅតាមមាត្រានិមួយៗ បានផ្ញើទៅកាន់គណៈកម្មធិការ ដែលពាក់ព័ន្ធនៅរដ្ឋសភាជាតិ ។ ការងារភាគច្រើនទាក់ទិននឹងច្បាប់បោះឆ្នោតក្រុមប្រឹក្សាឃុំ បានធ្វើដោយក្រុមត្រួតពិនិត្យការបោះឆ្នោតមានខុមហ្វ្រែល ខូហ្វែល និង និកហ្វិក។ គណៈកម្មការការពារជំលោះកំឡុងពេលបោះឆ្នោតក្រុមប្រឹក្សាឃុំ (COPCEL) បានអញ្ជើញមន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងគណៈបក្សនយោបាយជាមូលដ្ឋានជួបគ្នាប្រចាំខែ ដើម្បីពិភាក្សារៀបចំសំរាប់ការបោះឆ្នោត កិច្ចប្រជុំក្រោមអធិបតីភាពនៃមជ្ឈ មណ្ឌលកម្ពុជាដើម្បីដោះស្រាយជំលោះស្ថិតនៅ CDRI ។ ក្រុមការងារមួយ នៃអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកមាន សីលាការវឌ្ឍដំណាក់ ស្តារកម្ពុជា និងសន្តិសេនា បានបង្កើតគណៈកម្មការសិក្សាទៅលើ ថាតើអង្គការទាំងនេះ អាចផ្តល់វគ្គបណ្តុះបណ្តាលយ៉ាងដូចម្តេចទៅដល់ក្រុមប្រឹក្សាឃុំទាំងនោះ។

ក្រុមមួយមាន ១៦អង្គការមិនមែនរដ្ឋាភិបាលបានបង្កើតគំរោងគាំទ្រក្រុមប្រឹក្សាឃុំ (CCSP) ហើយអ្នកដឹកនាំក្រុម[៦] បានតែងតាំងសំរាប់រយៈពេល៦ខែដំបូងនៃការចាប់ផ្តើម ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០០។ ទីប្រឹក្សា នឹងរៀបចំបណ្តាញដែលមានស្រាប់នៅកម្ពុជាថែមទាំងនាំមកនូវមេរៀនពីប្រទេសផ្សេងទៀតដើម្បីផ្តល់ជា យុទ្ធសាស្ត្រទូលំទូលាយ សំរាប់អង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រក្រុមប្រឹក្សាឃុំ។

ថ្មីៗនេះគណៈប្រតិភូ UNDP[៧] បានផ្តល់មតិយោបល់ថាមាន "សេចក្តីត្រូវការ និងសក្តានុពលដ៏ធំសំបើម សំរាប់រាជរដ្ឋាភិបាល ក្នុងការបញ្ចូលសហគមន៍អង្គការមិនមែនរដ្ឋាភិបាល ទៅក្នុងដំណើរការកំនែទំរង់ វិមជ្ឈការ "យោងតាមហេតុផលដូចខាងក្រោម ៖

១- អង្គការមិនមែនរដ្ឋាភិបាល ជាញឹកញាយធ្លាប់ តែប្រតិបត្តិការផ្តល់សេវាកម្ម ក្នុងតំបន់ជនបទ នៅប្រទេសកម្ពុជា។

២- នៅក្នុងប្រទេសកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល ៣០-៥០% ប្រកបអាជីពផ្តល់ជំនួយការបច្ចេកទេសលើការចំណាយ។

៣- ការចំណាយ កំពុងកើនឡើងយ៉ាងឆាប់រហ័ស តាមរយៈអង្គការមិនមែនរដ្ឋាភិបាល។

---

[៦] លោក David M Ayres ធ្វើការនៅការិយាល័យ CIDSE ភ្នំពេញ e-mail: ccsp@bigpond.com.kh

[៧] Porter, Romeo និង Saigal pp19-20.

៤- អង្គការមិនមែនរដ្ឋាភិបាលមានទំនាក់ទំនងល្អជាមួយក្រសួងពាក់ពន្ធ័ នាយកដ្ឋាន និងជាមូដ្ឋានជំនាញមួយសំរាប់ការបណ្តុះបណ្តាល និងសំរបសំរួលធ្វើផែនការអភិវឌ្ឍន៍ដែលមានការចូលរួម ។

៥- អង្គការមិនមែនរដ្ឋាភិបាល បានរួបរួមគ្នាយ៉ាងទូលំទូលាយ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងឥទ្ធិពលភាពមូលដ្ឋាន ការចូលរួមក្នុងនយោបាយ និងការអភិវឌ្ឍន៍ ។

## ហេតុផលសំរាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចាប់ផ្តើមសកម្មភាពឥឡូវនេះ

ក្នុងកំឡុងឆ្នាំថ្មីនេះ វាបានក្លាយជាភាពងាយស្រួល សំរាប់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការនិយាយថា *"យើងធ្វើការងារអភិវឌ្ឍន៍ ហើយអាជ្ញាធរមូលដ្ឋានធ្វើការងាររដ្ឋាភិបាល"* ហើយក៏អាចនិយាយដែរថា *"យើងធ្វើការងារ អភិវឌ្ឍន៍ដែលមានភាពខុសគ្នាពីនយោបាយៈ យើងមិនធ្វើនយោបាយទេ"* ។ បើសិនជាក្រុមប្រឹក្សាឃុំជាអ្នកទទួលខុសត្រូវ ចំពោះការរៀបចំផែនការអភិវឌ្ឍន៍ និងផ្តល់សេវាកម្មផ្សេងៗ នៅក្នុងឃុំរបស់ពួកគេការបែងចែកការទទួលខុសត្រូវ នឹងមិនច្បាស់លាស់ ។ ប្រសិនក្រុមប្រឹក្សាឃុំគឺត្រូវបាន ជ្រើសតាំង នៅក្នុងការបោះឆ្នោតពហុបក្ស នៅពេលនោះការបែងចែករវាងនយោបាយនិងការអភិវឌ្ឍន៍ ក៏នឹងមិនច្បាស់លាស់ផងដែរ ។

អ្វីកើតឡើងក៏ដោយ គឺមានដំណើរកំពុងឈានទៅរកការប្រែប្រួលនៅក្នុងតួនាទី និងឥរិយាបទនៃអាជ្ញាធរ មូលដ្ឋាន ដូច្នេះហើយនឹងមានការប្រែប្រួល ដល់ទំនាក់ទំនងរវាង អង្គការមិនមែនរដ្ឋាភិបាល និង អាជ្ញា ធរមូលដ្ឋាន។ ថ្មីៗនេះ បទនិពន្ធនៃផ្នែកទ្រឹស្តីអភិបាលកិច្ចទូទាំងពិភពលោកផ្តល់យោបល់ថា អភិបាលកិច្ចមូលដ្ឋានមិនមែន និយាយត្រឹមតែអំណាច និងការទទួលខុសត្រូវនៃរដ្ឋការមូលដ្ឋាននោះទេ ។ តែនិយាយពីអំណាច និងការទទួលខុសត្រូវនៃរដ្ឋការមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន អង្គការប្រជាជនធ្វើការរួមគ្នា ។ នេះជាគំនិតថ្មីមួយនៅកម្ពុជា ដូចនេះគំនិតរីកចំរើនមួយចំនួនគឺត្រូវនឹកគិត ថាតើអំណាច និងការទទួលខុសត្រូវ ក្នុងការងារអភិបាលកិច្ចអាច ចែករំលែកយ៉ាងដូម្តេច ។

**ឱកាស**

ប្រយោជន៍ជាសក្តានុពលពីវិមជ្ឈការ សំរាប់អង្គការមិនមែនរដ្ឋាភិបាល រាប់បញ្ចូល :

- ក្រុមប្រឹក្សាឃុំអាចបង្កើតឡើងដូចជាអង្គការមូលដ្ឋាន ជាមួយក្តីកង្វល់ប្រហាក់ប្រហែលគ្នា បំផុតចំពោះអង្គការមិនមែនរដ្ឋាភិបាល អំពីការអភិវឌ្ឍន៍មូលដ្ឋាន ។ ១៦០០ ស្ថាប័នមូលដ្ឋាន ដែលជាផ្នែក នៃរដ្ឋអាចជាសម្ព័ន្ធមិត្ត មានតំលៃក្នុងគោលនយោបាយតស៊ូមតិ ។
- អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន ប្រឹងប្រែងពង្រឹងអំណាចសហគមន៍ ដើម្បីបានបញ្ចេញ ឥទ្ធិពលទៅលើសេចក្តីសំរេចចិត្តដែលមានផលប៉ះពាល់ដល់ពួកគេ ។ក្រុមប្រឹក្សានៅគ្រប់ឃុំ អ្នកមានធនធាន និងអ្នកមាន

កិច្ចការត្រូវឆ្លើយតបទៅ នឹងចំណង់ចំណូលចិត្តរបស់ប្រជាជន អាចធ្វើអោយមានភាពងាយស្រួលជាងសំរាប់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីមានឥទ្ធិពលនៃការលើក ស្ទួយអំណាចមូលដ្ឋាន ។

▪ បើសិនធនធានរដ្ឋាភិបាលគឺបាន ចែករំលែកសំរាប់ការ អភិវឌ្ឍន៍មូលដ្ឋាននេះបញ្ជាក់ អោយអង្គការមិនមែន រដ្ឋាភិបាលដឹងថា ការអភិវឌ្ឍន៍មូលដ្ឋានមិនមែនពឹងផ្អែកតែលើការវិនិយោគរបស់ អង្គការមិនមែនរដ្ឋាភិបាលនោះទេ ។ ចំណុចនេះ ធ្វើអោយមានភាពងាយស្រួលកាន់តែខ្លាំងឡើង សំរាប់ អង្គការមិនមែនរដ្ឋាភិបាលដកខ្លួនចេញពីសហគមន៍ ។

**ឧបសគ្គ**

ជាលក្ខណៈទូលំទូលាយ មានភាពប្រកបដោយគ្រោះថ្នាក់ពីរ ជាប់ពាក់ព័ន្ធនឹងកំនែទំរង់វិមជ្ឈការ ដែលប្រហែលជាមានផលប៉ះពាល់ជាអវិជ្ជមាន ដល់អង្គការមិនមែនរដ្ឋាភិបាល ។

• ប្រការ ដែលកំនែទំរង់អាចបរាជ័យ នោះ អាស្រ័យលើការខ្វះ ការគាំទ្រនាំទៅរកការដកខ្លួនចេញ ពីកិច្ចការនៅថ្នាក់ឃុំ ពីសំណាក់រដ្ឋាភិបាលកណ្តាល ហើយផ្តល់អោយពួកគេវិញ នូវការគ្រប់គ្រង ក៏វិតខ្ពស់ ដូច្នេះ បាត់បង់ឱកាសគាំទ្រ ដែលបានលើកឡើងខាងលើ ។ ក៏មានមតិយោបល់បានផ្តល់ ដែរថាអង្គការមែនរដ្ឋាភិបាលខ្លួនឯងប្រហែលនឹងជាកត្តាមួយក្នុងការបណ្តាលអោយកំនែទំរង់វិមជ្ឈការទទួលបរាជ័យកាល ណាបើអង្គការទាំងនោះ មិនគាំទ្រពួកគេ ។

• ម្យ៉ាងវិញទៀតមានឧបសគ្គមួយចំពោះឯករាជ្យ ភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ។ បើសិនក្រុមប្រឹក្សាឃុំជាអ្នកទទួលខុសត្រូវជា " ភ្នាក់ងារថ្នាក់ក្រោមបំផុត នៃការអភិវឌ្ឍន៍មូលដ្ឋាន" ក្នុងឃុំនិមួយៗ ពួកគេប្រហែលជាសម្ព័ន្ធមិត្តត្រាទាំង ផ្នែករដ្ឋាភិបាល និងផ្នែក អង្គការមិនមែនរដ្ឋាភិបាល (ឬស្ម័គ្រចិត្ត) ។ វានឹងបែបនេះគឺសំខាន់ សំរាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងការបញ្ចុះបញ្ចូលរដ្ឋាភិបាល នៅថ្នាក់មូលដ្ឋាន និងនៅថ្នាក់ជាតិអោយមាន ជំនឿលើគុណសម្បត្តិសំរាប់ការ អភិវឌ្ឍន៍ជាតិដោយមានវិស័យអង្គការមិន មែនរដ្ឋាភិបាល យ៉ាងសកម្មមួយចូលរួម ដែលអង្គការ មិនមែនរដ្ឋាភិបាល មានសេរីភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាព ។

បើអង្គការមិនមែនរដ្ឋាភិបាល គិតអំពីបញ្ហាទាំងនេះជាមុន ហើយចាប់ផ្តើមការងារស្រាវជ្រាវ ព្រមទាំងកសាងទំនាក់ទំនង និងបណ្តាញការងារផ្ទាល់ខ្លួនរបស់ពួកគេ គឺមានសំណាងច្រើនដែលថាពួកគេនឹងអាច រកផ្លូវដើម្បី មានតួនាទីសំខាន់មួយក្នុងកិច្ចការអភិបាលកិច្ចមូលដ្ឋាន ។ ផ្នែកទី៤ នៃឯកសារនេះនឹងសំឡឹង មើលអំពីថាតើ អង្គការមិនមែន រដ្ឋាភិបាលអាចត្រៀមខ្លួនយ៉ាងដូចម្តេច ដើម្បីបញ្ចេញឥទ្ធិពលភាពចំពោះ ការបង្កើតគោលនយោបាយ ។ ដំបូងត្រូវគិតថា វានឹងសំឡឹងមើលសកម្មភាព នៃអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការអភិវឌ្ឍន៍នៅមូលដ្ឋាន អាចធ្វើការរៀបចំខ្លួនរបស់គេ សំរាប់កំនែទំរង់អភិបាលកិច្ចឃុំ ។

## អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការអភិវឌ្ឍន៍នៅមូលដ្ឋាន និងកំណែទំរង់ថ្នាក់ឃុំ

### ពង្រឹងទំនាក់ទំនងជាមួយមន្ត្រីថ្នាក់ឃុំ និងអ្នកនយោបាយ

### តំរូវការ និង ឱកាស

នាពេលអនាគត ឃុំកំពុងឈានទៅរកការមានតួនាទីមួយ កាន់តែសំខាន់ឡើង ក្នុងការងារអភិបាលកិច្ច មូលដ្ឋាន ជាពិសេស ក្នុងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន ។មានអាទិភាពក្នុងការអនុម័តច្បាប់ឃុំថ្មី ដែលទូនាទីនេះ នឹងត្រូវបាន បំពេញដោយអាជ្ញាធរឃុំដែលមានស្រាប់និងដោយគណៈកម្មការអភិវឌ្ឍន៍ឃុំនៅទីណាដែលមានពួកគេ( ឧទាហរណ៍ បុគ្គលិកឃុំ ដែលមានស្រាប់កំពុងធ្វើការជាមួយប្រធានគណៈកម្មការ អភិវឌ្ឍន៍ភូមិដែលបានជ្រើសរើសឡើង) បន្ទាប់ពីការអនុម័តច្បាប់និងការបោះឆ្នោតឃុំក្រុមប្រឹក្សាឃុំនឹងបំពេញតួនាទីនោះ ។ដូច្នេះពេលនោះ គឺនឹងមានយ៉ាង ជាក់ច្បាស់នូវតំរូវការមួយសំរាប់អង្គការមិនមែន រដ្ឋាភិបាលកសាងភាពជាដៃគូរជាមួយស្ថាប័នថ្នាក់ឃុំ ។

### ការរៀនសូត្រពីគ្នាទៅវិញទៅមករវាងឃុំ និងអង្គការមិនមែនរដ្ឋាភិបាល

បច្ចុប្បន្ន អង្គការមិនមែនរដ្ឋាភិបាលជាច្រើន កំពុងសំដែងសេចក្តីគោរពយ៉ាងត្រឹមត្រូវចំពោះប្រធានឃុំ ហើយ កំពុង ធ្វើអោយប្រាកដថា ពួកគេមានចំណងមិត្តភាពការងារសមរម្យជាមួយប្រធានឃុំទាំងនោះ ។ ទោះយ៉ាង ណាបុគ្គលិកអង្គការ មិនមែនរដ្ឋាភិបាលអាចរៀនបានច្រើនអំពីការងារបស់ប្រធានឃុំ និង ប្រធានឃុំអាចរៀន បានច្រើនពីការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលអាចផ្តល់ប្រយោជន៍ដល់មនុស្សគ្រប់គ្នានៅពេលអនាគត ។

គុណតំលៃជាច្រើនចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលយល់ព្រមចុះ សំរុងគ្នាចំពោះ ការបើកចំហដោយឥត លាក់លៀម និងការធានាខុសត្រូវ ។ អាស្រ័យទៅលើអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីឃុំផងដែរវាប្រហែលជា មានឱកាសសំរាប់ អង្គការមិនមែនរដ្ឋាភិបាលបង្ហាញ នូវគុណតំលៃទាំងនេះដោយអញ្ជើញមន្ត្រីឃុំ រៀនសូត្រ អោយច្រើនអំពីការងាររបស់អង្គការ ។ហេតុកាណ៍ នេះអាចកើតឡើង ជាឧទាហរណ៍ដោយអញ្ជើញមន្ត្រី ឃុំដោយ ចំណាយមួយឬពីរសប្តាហ៍អោយ បានជាប់ចិត្ត និងគំរោងឬធ្វើសាមញ្ញជាងនេះអញ្ជើញពួកគាត់ចូលរួមក្នុង "ថ្ងៃ ប្រកាសជាចំហរ" មួយគឺទីណាដែលពួកគេអាចមើល របាយការណ៍គំរោងកម្មវិធី ឯកសារកត់ត្រាគណៈនេយ្យហើយ យល់ឆ្លុះជ្រៅបានថែមទៀត ទៅដល់ អង្គការមិនមែនរដ្ឋាភិបាលចាត់ចែងសកម្មភាព ការងារអភិឌ្ឍន៍ របស់ខ្លួន យ៉ាងដូចម្តេច ។ ការរៀនសូត្រជាផ្លូវការសំខាន់ជាងគេ អំពីការងារដែលអង្គកាមិនមែនរដ្ឋាភិបាលភាគច្រើនទទួល ខុស ត្រូវគឺការវាយតំលៃទាំងការវាយតំលៃ (ខាងក្នុងនិងខាងក្រៅ) ។ វិធីជាទំលាប់មួយនៃការចែករំលែក គំនិត និងចំណេះដឹងជាមួយមន្ត្រីឃុំ តែងតែជាការអញ្ជើញពួកគាត់ចូលរួមក្នុងក្រុម ដែលធ្វើការវាយតំលៃការងាររបស់ អង្គការ ។ ស្រដៀងនេះដែរក្នុង ករណីអង្គកាមិនមែនរដ្ឋាភិបាលចូលរួមក្នុងទស្សនៈកិច្ចសិក្សាទៅខេត្តមួយផ្សេងៗ ទៀត ហើយរិតតែប្រសើរនោះគឺអ្នកភូមិទៅស្នាក់នៅអ្នកភូមិផ្សេងទៀតហើយ និង អ្នកធ្វើការងារអភិឌ្ឍន៍ទៅ

ស្នាក់នៅជាមួយអ្នកធ្វើការងារអភិឌ្ឍន៍ប្រធានឃុំអាចត្រូវបានអញ្ជើញអោយទៅ ស្នាក់នៅជាមួយប្រធានឃុំនៅខេត្ត ដ៏ទៃទៀត។

ប្រសិនបើទំនាក់ទំនងមិត្តភាព ល្អអង្គការមិនមែនរដ្ឋាភិបាល ប្រហែលជាអាចរៀនសូត្រ ច្រើន ផងដែរ អំពីការទទួលខុសត្រូវ នៃប្រធានឃុំ : អំពីការលំបាកដែល ពួកគេជួបប្រទះ និងអំពីគោលគំនិត ដែលពួកគេមានសំរាប់ ការអភិឌ្ឍន៍ឃុំនាពេលអនាគត ។

**ការជួយគ្នាទៅវិញទៅមក នៃអង្គការមិនមែនរដ្ឋាភិបាល និងឃុំ**

ពេល ដែលការផ្លាស់ប្តូរពត៌មានប្រយោជន៍ ចំណងមិត្តភាព នឹងបានរឹងមាំឡើងយ៉ាងប្រាកដនៅពេល ដែលប្រជាជនចាប់ផ្តើមជួយគ្នាទៅវិញទៅមក។ មានឱកាសមួយសំរាប់អង្គការមិនមែនរដ្ឋាភិបាល និងអង្គាធរ ឃុំដើម្បីកំណត់ និងសំរេចបានគោលបំណងរួម ។ ទាំងនេះ ធ្វើបានយ៉ាងងាយ នៅតាមតំបន់ ដែល កម្មវិធី សីលាធ្វើការ ទីណាដែលគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សុខចិត្តទុកឱកាសសំរាប់កិច្ចកិច្ច ជំនួយការនេះ និងគណៈកម្មការអភិឌ្ឍន៍ឃុំមានការមមាញឹកជាមួយនឹងកិច្ចទទួលខុសត្រូវក្នុងការងារអភិវឌ្ឍន៍ ហើយប្រហែលជាត្រេកអរក្នុងការជួយ។ យ៉ាងណាក៏ដោយ ឱកាសក៏មានផងដែរនៅក្នុងឃុំ ដែលគ្មានកម្មវិធី សីលា។

ច្បាស់ណាស់ថា ជំនាញ និងបណ្តាញការងារជាច្រើន ដែលអង្គការមិនមែនរដ្ឋាភិបាលមាន អាចជាប្រយោជន៍ចំពោះមន្ត្រីឃុំ។ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាលជាញឹកញយមានការយល់ដឹងល្អអំពី អង្គការម្ចាស់មូលនិធិផ្សេងៗ: តើអាចទៅរកពួកគេបានយ៉ាងដូចម្តេចហើយ គំរោងប្រភេទណា ដែលពួកគេនឹងផ្តល់ មូលនិធិ ។ល។ការចែករំលែកចំណេះដឹងទាំងនេះប្រហែលជាគ្មានចំណាយអ្វីចំពោះ អង្គការមិនមែនរដ្ឋាភិបាល ទេ ប៉ុន្តែប្រហែលជាអាចជួយបង្កើតនូវទំនាក់ទំនងយ៉ាងល្អបំផុត។

អាចជាឱកាសផងដែរសំរាប់ អង្គការមិនមែនរដ្ឋាភិបាល ជួយក្នុងការឃោសនាបោះឆ្នោត។ ទាំងនេះអាចជួយសង្កត់បញ្ជាក់ថា គោលនយោបាយមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន គឺជាពិសេសនិយាយអំពីការ អភិវឌ្ឍន៍ ។ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើការជាមួយជនចាស់ជរារៀបចំកិច្ចពិភាក្សាក្រុមតូចមួយចំនួននៅត្រង់កន្លែងណាដែលបេក្ខជននាំមុខមកពីគណៈបក្សផ្សេងៗគ្នាចូលរួមស្តាប់ ក្រុមតូចៗនៃជនចាស់ជរា ជជែកអំពីការព្រួយបារម្ភនៅក្នុងជីវភាពរស់នៅរបស់ពួកគេ ។ ( បើសិនជាមាន ប្រព័ន្ធតំណាងសមាមាត្រ ចំណុចនេះ ក៏នឹងមិនសូវមានវាទប្បដិវាទនឹងគ្នាផង ដែរ ដោយហេតុថា បុគ្គល ដែលមានឈ្មោះ ស្ថិតនៅខាងលើគេក្នុងបញ្ជីរាយនាម បេក្ខជនរបស់គណៈបក្ស គឺទំនងជា ចង់មានកៅអីនៅក្នុងក្រុមប្រឹក្សា) ។ សកម្មភាពបែបហ្នឹង អាចជាគុណតំលៃផងដែរ

ក្នុងការកសាងចំណង ទាក់ទងរវាងឃុំ និងប្រជាជន ហើយជាពិសេសក្នុងការធ្វើអោយប្រាកដថា អ្នកក្រ ភាគតិច (ដូចជា ប្រជាជនដែលគ្មានដីធ្លី ប្រជាជនពិការ ប្រជាជនចាស់ជរា។ល។) គឺមិនត្រូវបានបំភ្លេចចោលដោយមន្ត្រីឃុំ។

ប្រភេទខុសៗគ្នានៃកិច្ចសហការទាំងនេះអាចជាគុណតំលៃទាំងនៅថ្នាក់មូលដ្ឋាននិងនៅថ្នាក់ជាតិ។នៅឯថ្នាក់មូលដ្ឋាន វាអាចជួយសង្កត់បញ្ជាក់ពីសារៈសំខាន់នៃការងារអភិវឌ្ឍន៍នៅក្នុងអភិបាល កិច្ចឃុំ ដូច្នេះ សារៈសំខាន់នៃអ្នកធ្វើការងារអភិវឌ្ឍន៍ផ្សេងគ្នា (មន្ត្រីឃុំ និង អង្គការមិនមែនរដ្ឋាភិបាល) គឺត្រង់ ធ្វើការជាមួយគ្នាទៅវិញទៅមក។ នៅឯថ្នាក់ជាតិ ប្រសិនបើ នីតិពន្ធថ្នាក់ជាតិ ទទួលរបាយការណ៍ពី តំបន់មូលដ្ឋាន អំពីការរួមចំណែកជាវិជ្ជមាន ដែលអង្គការមិនមែនរដ្ឋាភិបាលកំពុងធ្វើចំពោះអភិបាល កិច្ចមូលដ្ឋាន ដែលនឹងជំរុញពួកគេក្នុងការសសេរច្បាប់ ដែលបង្ករឱកាសសំរាប់ការចូលរួមរបស់ អង្គការ មិនមែនរដ្ឋាភិបាល។

ពេលដែលវាមានសារៈសំខាន់ដើម្បីកសាងចំណងទាក់ទង ជាមួយអាជ្ញធរដែលមានស្រាប់ វាក៏មានសារៈ សំខាន់ផងដែរដែលអ្នកធ្វើការងារអង្គការមិនមែនរដ្ឋាភិបាល បង្កើតទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេ នូវអ្វី ដែលពួកគេចង់អោយថ្នាក់ឃុំនៃរដ្ឋាភិបាលទទួលខុសត្រូវចំពោះ។ ជាមួយនឹងទស្សនៈអ្វី ដែលអង្គការ មិនមែនរដ្ឋាភិបាល អាចចាប់ផ្តើមគិតអំពីយុទ្ធសាស្ត្រ ដែលពួកគេត្រូវការក្នុងរយៈពេលខ្លី ដើម្បីកសាង ប្រភេទចំណងទាក់ទងដែលពួកគេប្រាថ្នាចង់បាន។

**បង្កើតទស្សនៈមួយនៃតួនាទីថ្នាក់ឃុំ**

ជាងម្ភៃឆ្នាំកន្លងទៅ មន្ត្រីឃុំមិនបានមានតួនាទី ដឹកនាំនៅក្នុងការអភិវឌ្ឍន៍ មូលដ្ឋាន ច្រើនតែដោយសារ ពួកគេមិនដែលមានធនធានដើម្បីបំពេញទូនាទីនេះ។ តួនាទីនៃការដឹកនាំក្នុងការអភិវឌ្ឍន៍ នឹងជារឿងថ្មី ចំពោះមន្ត្រីឃុំ (នៅក្នុងគណៈកម្មការអភិវឌ្ឍឃុំ ឬក្រុមប្រឹក្សាឃុំ)។ ពួកគេជាធម្មតានឹងចាប់ផ្តើមដោយ សមត្ថភាពទាបបំផុត ហើយប្រការនេះជាធម្មតានឹង កើនបទពិសោធន៍យ៉ាងឆាប់រហ័សបំផុត។ គំនិត អំពីអ្វីដែលឃុំអាច ឬគួរតែធ្វើ នឹងប្រែប្រួលពីពេលមួយទៅពេលមួយ ។ ខាងក្រោមនេះជាគោលគំនិត មួយចំនួនដែលអ្នកធ្វើការងារ អង្គការមិនមែនរដ្ឋាភិបាល ប្រហែលជាគិតអំពីពេលពួកគេព្យាយាម បង្កើតទស្សនៈដំបូងមួយ នៃប្រភេទតួនាទីនិងការទទួលខុសត្រូវដែលឃុំគួរតែមាន។

**តួនាទី នៃស្មៀនឃុំ**

ប្រសិនបើ ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំត្រូវបានអនុម័តតាមទំរង់ថ្មីរបស់ខ្លួន ក្រុមប្រឹក្សាឃុំនឹងទទួលបាន ផងដែរនូវការបំរើនៃស្មៀនឃុំ ដែលបានតែងតាំងដោយក្រសួងមហាផ្ទៃ ។ តើមនុស្សប្រភេទណា ដែល អង្គការមិនមែនរដ្ឋាភិបាលគិតថាអាចនឹងមានតំលៃសំរាប់ការងារនេះ ? វគ្គបណ្តុះបណ្តាលប្រភេទអ្វី ដែលក្រសួងមហាផ្ទៃ គួរតែផ្តល់ដល់ពួកគេ? ពួកគេគួររស់នៅកន្លែងណា? ។

**មុខងារនាក់ទិននឹងមូនិធិអភិវឌ្ឍន៍មូលដ្ឋាន**

មូនិធិអភិវឌ្ឍន៍មូលដ្ឋាន គឺត្រូវបានគ្រោងទុកក្នុងពង្រៀងច្បាប់ឃុំ ហើយកំពុងត្រូវបានវិនិច្ឆ័យផងដែរ ក្នុង កម្មវិធីសីលារបស់រាជរដ្ឋាភិបាល( សូមមើលខាងក្រោម) ។ ក្នុងទស្សនៈថ្មីនៃកម្មវិធីសីលាគណៈកម្មការអភិវឌ្ឍន៍ភូមិគឺត្រូវបានត្រួតពិនិត្យយ៉ាងប្រកៀកប្រកិតពេញទី ពីមន្ត្រីថ្នាក់ខេត្ត ។ លុយសំរាប់គំរោង ត្រូវបានចំណាយចេញពីគណៈនីធនាគាខេត្ត ចូលទៅក្នុងគណនីធនាគារបស់អ្នកទទួលម៉ៅការ ដោយសែក កាលណា ការចំណាយ បានចុះហត្ថលេខាព្រមព្រៀងដោយប្រធានឃុំ ។ តើធ្វើបែបនេះគឺមានគុល្យភាពល្អ ចំណោមអ្នកចូលរួម ផ្សេង១ឬគួរតែឃុំទទួលលុយដែល គឺអាស្រ័យទៅលើពួកគេ ជាអ្នកលែលកបង្កើត ការចំណាយផ្ទាល់ខ្លួន របស់ពួកគេ ? បើសិនដូច្នោះតើការអនុវត្ត បែបនេះគួរអោយចង់បានក្នុងរយៈ ពេលឆាប់១ ឬលុះត្រាតែនៅ ពេលវេលាខ្លះ ក្នុងពេលអនាគត? ។

**ឃុំ និង ការយកពន្ធ**

ឆ្លងកាត់ពេលវេលាមួយរយៈ ឃុំនឹងបង្កើតសិទ្ធិ និងការទទួលខុសត្រូវ សំរាប់ការប្រមូលពន្ធ ។បច្ចុប្បន្ន មានហើយជាស្រេចនូវ ការប្រមូលពន្ធក្រៅផ្លូវការមួយចំនួន នៅក្នុងឃុំជាច្រើន ។ ការយកពន្ធ គួរតែផ្តល់ វិញ ជាសំណងនូវសេវាកម្ម : ប្រជាជន ដែលបង់ពន្ធគឺភាគច្រើនក្រោយមក ប្រហែលជាសកម្ម ក្នុងការ ធ្វើអោយប្រាកដថាសេវាសមរម្យត្រូវបានគេផ្តល់អោយ ។ ការប្រមូលពន្ធនៅមូលដ្ឋាន ពង្រីកវិសាលភាព នៃការពឹងផ្អែក របស់រដ្ឋការមូលដ្ឋានទៅលើប្រជាជនមូលដ្ឋាន ជាជាងពឹងផ្អែកលើថ្នាក់លើនៃ រដ្ឋាភិបាល ។

តើពន្ធ ប្រភេទអ្វី ដែលគួរតែឃុំមានសិទ្ធិ និងការទទួលខុសត្រូវក្នុងការប្រមូល? តើពួកគួរតែប្រើប្រាស់ សំរាប់អ្វី? អ្វី នឹងជាវិធីសាស្រ្តល្អបំផុតសំរាប់ផ្លាស់ គណៈនេយ្យ និងពន្ធ សំងាត់ក្រៅផ្លូវការដែលមាន ស្រាប់ទៅក្នុងប្រព័ន្ធផ្លូវការ និងតម្លាភាព នៃការយកព័ន្ធនៅមូលដ្ឋាន? ។

**មុខងារនាក់ទិននឹងការគ្រប់គ្រងធនធានធម្មជាតិ**

ពង្រាងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ ផ្តល់អាទិភាពចំពោះតួនាទីរបស់ឃុំ នៅក្នុងផែនការអភិវឌ្ឍន៍ និង ចាត់ចែងថវិកាអភិវឌ្ឍន៍ ។ទោះជាយ៉ាក៏ដោយមានចំនុចសំខាន់ដ៏ផ្សេងទៀត នៃអភិបាលកិច្ច ស្ថិតនៅក្នុងអ្វីដែល រដ្ឋការមូលដ្ឋានអាចដើរតួនាទីសំខាន់ ។ នៅផ្នែកមួយនៃពង្រៀងច្បាប់ បានសំដែងការវែកញែកសេចក្តីអំពីការថែទាំបរិស្ថាន និងធនធានធម្មជាតិ ហើយនៅផ្នែកផ្សេងទៀត និយាយថាឃុំនឹងគ្មាន យុត្តាធិការ (អំណាចផ្លូវច្បាប់) កាន់កាប់ទៅលើព្រៃឈើទេ ។

តើអង្គការមិនមែនរដ្ឋាភិបាលនឹងចង់ឃើញឃុំមានតួនាទី នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ រឹងមាំឡើងទៅដល់កំរិតណា? ក្នុងករណីណាដែល សហគមន៍សហការគ្រប់គ្រង គឺកំពុងតែត្រូវបានជំរុញអោយចំរើនឡើង តើវានឹងជាការប្រសើរសំរាប់ សហគមន៍ធ្វើកិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ ឬ ជាមួយថ្នាក់បញ្ជារពីខាងលើនៃរដ្ឋាភិបាល

(ដូចជា ថ្នាក់ខេត្ត) ឬយ៉ាងណា? តើការគ្រប់គ្រង និងកិច្ចសហការផ្ទៃក្នុងរបស់ឃុំ អាចទៅរួចចំពោះករណីមួយចំនួន (ឧទាហរណ៍ដូចជា ផ្លូវទឹកដែលហូរកាត់ ៤ទៅ៥ឃុំ)? តើវានឹងគួអោយប្រាថ្នាចង់បាន? ។

### តំណាងរដ្ឋ និង តំណាងប្រជាជន

នៅក្នុងផ្នែកដទៃទៀតនៃពិភពលោក លក្ខណៈសំខាន់ពិសេសជាច្រើននៃសង្គមស៊ីវិល គឺកំពុងបានពង្រីកទៅក្នុងរដ្ឋាភិបាល។ រដ្ឋការមូលដ្ឋានកំពុងភ្ជាប់បណ្តាញការងារ ស្វែងរកមូនិធិពីម្ចាស់ជំនួយផ្សេងៗ និង កំពុងចូលរួមក្នុងការ បញ្ចុះបញ្ចូល និងការតស៊ូមតិ។ តើអង្គការមិនមែនរដ្ឋាភិបាលនឹងស្វាគមន៍ក្រុមប្រឹក្សាឃុំ ដែលមានឥរិយាបថបែបនេះ ឬពួកគេនឹងចូលចិត្តចង់អោយក្រុមប្រឹក្សាឃុំ មានតួនាទីដែលនៅមានតំរិត ហើយមានលក្ខណៈច្រើនជាប្រពៃណី ជាង? ។

### ឃុំ និង អង្គការមិនមែនរដ្ឋាភិបាល

តើអង្គការមិនមែនរដ្ឋាភិបាល ចង់អោយទំនាក់ទំនងរបស់ពួកគេជាមួយឃុំ ត្រូវបានដាក់កំរិតយ៉ាងដូចម្តេច? តើគួរតែមានច្បាប់ផ្លូវការ ឬ ច្បាប់ផ្លូវការសំរាប់តែថ្នាក់ខ្ពស់ ហើយក្រុមប្រឹក្សាឃុំ និង អង្គការមិនមែនរដ្ឋាភិបាលគួរតែធ្វើកិច្ចព្រមព្រៀងថ្នាក់មូលដ្ឋានផ្ទាល់ខ្លួនរបស់ពួកគេ ទៅតាមកាលៈទេសៈរបស់ខ្លួន?

បើសិនអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការអភិវឌ្ឍន៍នៅមូលដ្ឋាន ចាប់ផ្តើមគិតអំពីបញ្ហាខាងលើឥឡូវនេះ ពួកគេ នឹងស្ថិតនៅក្នុងស្ថានភាពយ៉ាងល្អដើម្បីរួមចំណែកកិច្ចសន្ទនា ពេលពួកគេត្រូវបានអញ្ជើញអោយចូលរួមក្នុងបណ្តាញការងារ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើបញ្ហាគោលនយោបាយ និង ក្នុងកិច្ចពិភាក្សាជាមួយរដ្ឋាភិបាល។ ផ្នែកបន្តបន្ទាប់ទៀតនិយាយខ្លីៗទៅលើ របៀបរៀបចំនៃអង្គការមិនមែនរដ្ឋាភិបាលជាតិដែលប៉ុនប៉ង បញ្ចេញឥទ្ធិពលភាពទៅគោលនយោបាយរដ្ឋាភិបាល ស្តីអំពីវិមជ្ឈការ ដែលអាចកំពុងធ្វើក្នុងពេលបច្ចុប្បន្ន។

### ការរៀនសូត្រ អំពីកម្មវិធីសីលា

#### ហេតុអ្វីបានជាកម្មវិធីសីលាសំខាន់ចំពោះអង្គការមិនមែនរដ្ឋាភិបាល?

ចាប់តាំងពីឆ្នាំ១៩៩៦ កម្មវិធីសីលាបានអនុវត្តក្នុងខេត្ត ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និង រតនៈគិរី។ សីលាត្រូវបានរៀបចំឡើងជា "ការដកពិសោធន៍គោលនយោបាយ ក្នុងអភិបាលកិច្ចវិមជ្ឈការ" មួយ។ ប្រការនេះអាចនិយាយបានថា ជាការបង្កើតគោលនយោបាយពីក្រោមឡើងលើមួយ។ ក្នុងពាក្យដទៃទៀត ភូមិ ឃុំ និងខេត្ត ដែលកម្មវិធីសីលាមាននៅក្នុងនោះចាប់ផ្តើមមានបទពិសោធន៍ជាមួយនឹងវិមជ្ឈការ ហើយបន្តិចម្តងៗ លទ្ធផលនៃបទពិសោធន៍ទាំងនេះត្រូវបានពិភាក្សានៅថ្នាក់ជាតិ។ ដូច្នោះហើយ ពេលសីលាចាប់ផ្តើមមាននៅក្នុងខេត្តនាឆ្នាំ១៩៩៦ កងកំលាំងកិច្ចការពិសេសរបស់សីលាដែលទទួលខុសត្រូវចាត់ចែងកម្មវិធីសីលា នៅឯថ្នាក់ជាតិ ទើបតែត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៨ ទេ។

បច្ចុប្បន្នកម្មវិធីសីលា ផ្តល់គំរូដែលអាចទទួលយកបានយ៉ាងល្អបំផុត ដើម្បីបង្ហាញថាតើ អភិបាលកិច្ចក្រោមច្បាប់ឃុំថ្មី វាដូចជាអ្វី។ ដូចគ្នានឹងកម្មវិធីអភិវឌ្ឍន៍ផ្សេងទៀត សីលា បានទទួលបានជោគជ័យជាច្រើន ហើយជួបប្រទះការលំបាកក៏ច្រើនផងដែរ។ វាមានសារៈសំខាន់ មិនមែនព្រោះតែវាល្អប្រសើរជាងកម្មវិធីផ្សេងទៀតនោះទេ ប៉ុន្តែដោយសារវាជាកម្មវិធីអភិវឌ្ឍន៍មួយដែលបានផ្តោតទៅលើឃុំ ហើយដែលបានធ្វើជាគំរូ តួនាទីសំរាប់ថ្នាក់ឃុំក្នុងការងារអភិវឌ្ឍន៍។ ដូច្នេះ តាមរយៈការសិក្សាកម្មវិធីសីលា អង្គការមិនមែនរដ្ឋាភិបាលអាចមើលឃើញផ្លូវនៅក្នុងអ្វីដែលពួកគេ ប្រហែលជាមានតួនាទីដែលមានប្រយោជន៍ នៅក្នុងអភិបាលកិច្ចឃុំ នៅពេលកំនែទំរង់ថ្នាក់ឃុំបានអនុវត្តន៍។

និយាយម្យ៉ាងទៀត ផ្លូវមួយសំរាប់អង្គការមិនមែនរដ្ឋាភិបាលរៀនសូត្រអំពីការផ្លាស់ប្តូរ ដែលនឹងកើតមានឡើងជាលទ្ធផលនៃកំនែទំរង់ថ្នាក់ឃុំ គឺរៀនច្រើនអំពីអ្វីបាន និងកំពុងកើតមានឡើងនៅក្នុងឃុំដែលមានបទពិសោធន៍នៃកម្មវិធីសីលារួចហើយ ។ រំលងរយៈពេល ៥ឆ្នាំបន្ទាប់ទៀត កម្មវិធីសីលាគឺត្រូវបានពង្រីកតាមកាលៈទេសៈទៅគ្រប់ឃុំទាំងអស់ នៅក្នុង ខេត្តចំនួន ១៧។ អញ្ចឹង សំរាប់អង្គការមិនមែនរដ្ឋាភិបាលភាគច្រើន ការងាររបស់ពួកគេនឹងបានចាប់ផ្តើមអនុវត្តន៍ក្នុងតំបន់សីលា នាអនាគតដ៏ខ្លីខាងមុខ។

**អ្វីជាគន្លឹះសំខាន់ជាងគេ នៃកម្មវិធីសីលា?**

ការផ្តោតជាសំខាន់នៃកម្មវិធីសីលាគឺឃុំ។ ស្នាដៃជាចំបងនៃកម្មវិធីសីលា នៅថ្នាក់ស្រុក និងថ្នាក់ខេត្តបានទទួលដោយអនុលោមតាម ការពង្រឹងសមត្ថភាពនៃមន្ត្រីថ្នាក់ខ្ពស់ទាំងនោះអោយគាំទ្រថ្នាក់ឃុំ។ យន្តការបង្កើតឡើងដោយឃុំណាមួយ បានសំរេចគឺត្រូវបានហៅថា របៀបធ្វើផែនការនូវតាមមូលដ្ឋាន (LPP)។ ជំហ៊ាននៃ របៀបធ្វើផែនការនូវតាមមូលដ្ឋានរបស់សីលា គឺត្រូវភ្ជាប់ជាសេចក្តីបន្ថែមជាមួយរបាយការណ៍នេះ។ ក្នុងសិក្ខាសាលានាពេលថ្មីនេះ ទស្សនៈនៃរបៀបធ្វើផែនការនូវតាមមូលដ្ឋាន (LPP) របស់សីលាត្រូវបានបង្ហាញអោយដឹងដូចខាងក្រោម:

*"ឃុំមួយដែលគ្រប់គ្រងដោយប្រជាធិបតេយ្យ ជាឃុំដែល ប្រជាជន សង្គមស៊ីវិល វិស័យឯកជន និង អាជ្ញធររដ្ឋាភិបាល ចូលរួមក្នុងការអភិវឌ្ឍន៍មូលដ្ឋាន។ ឃុំចាត់ចែងការងារអភិវឌ្ឍន៍ យ៉ាងមាន តម្លាភាព សមធម៌ ប្រសិទ្ធិភាព ដើម្បីពង្រឹង សន្តិភាព និង យុត្តិធម៌ និងដើម្បីបង្កើតការរីកចំរើនជានិរន្ត នៅក្នុងជីវិតរស់នៅរបស់ប្រជាជន "។*

ចំណុចសំខាន់ជាងគេភាគច្រើននៃរបៀបធ្វើផែនការនូវតាមមូលដ្ឋាន (LPP) ជារៀងរាល់ឆ្នាំ ឃុំនិមួយៗ ត្រូវលៃលកថវិការសំរាប់អភិវឌ្ឍន៍ឃុំ ( មូនិធិអភិវឌ្ឍន៍មូលដ្ឋាន ឬ ហៅថា LDF)។ វាជាការទទួលខុសត្រូវរបស់ឃុំក្នុងការពិភាក្សាជាមួយប្រជាជនក្នុងឃុំ ដើម្បីបង្កើតផែនការសំរាប់វិនិយោគលុយនេះ អាស្រ័យលើអាទិភាពរបស់ប្រជាជនក្នុងឃុំ។ ដូច្នេះតាមវិធីនេះ កម្មវិធីសីលា ត្រូវបានគេសង្ឃឹមថាជួយលើកស្ទួយកិច្ចសហការរវាងរដ្ឋ និងសង្គម។

នៅពេលបច្ចុប្បន្នខេត្តនៅតែមានតួនាទីក្នុងការគ្រប់គ្រងយ៉ាងខ្លាំងនៅក្នុងដំណើការផែនការមូលដ្ឋាន ។ គំរោងផែនការនានាត្រូវបាន ផ្ញើរ ទៅដោយឃុំ ទៅកាន់ខេត្តដើម្បី សុំការឯកភាពដូចគ្នានេះ ដែរគំរោងជាបុគ្គល ដែលឃុំមានបំណងអនុវត្តនី ត្រូវតែមានការយល់ព្រមដោយខេត្ត (ខេត្តគ្រាន់តែមានសិទ្ធិ ធ្វើការបដិសេធនីការយល់ព្រមលើមូលដ្ឋានបច្ចេកទេសប៉ុណ្ណោះ) ។ មូលនិធិអភិវឌ្ឍន៍ឃុំ មិនត្រូវបានផ្តល់ទៅអោយឃុំ នៅដើមឆ្នាំ នោះទេ វាត្រូវបានចំណាយដោយខេត្ត ទៅអោយអ្នកម៉ៅការបន្ត បន្ទាប់ពីគណៈកម្មការអភិវឌ្ឍន៍ឃុំ បានយល់ព្រមទៅលើគំរោងរបស់ឃុំ ផ្ទុយទៅវិញ ស្រុកមិនមានតួនាទីគ្រប់គ្រងខ្លាំង នៅក្នុងកម្មវិធីសិលាទេ ប៉ុន្តែវាមានសារៈសំខាន់សំរាប់ផ្តល់នូវការសំរបសំរួល និងថែមទាំង ផ្តល់នូវការឧបត្ថម្ភគាំទ្រ និង សំរបសំរួលខាងបច្ចេកទេស ។

ផ្នែកនៅសល់នៃផ្នែកតូច ត្រូវបានលើកឡើងនៅក្នុងចំណុចសំខាន់១ នៃ ដំណើការផែនការមូលដ្ឋាន និងជាពិសេសសំរាប់ជាមធ្យោបាយដែលអង្គការក្រៅរដ្ឋាភិបាល អាចធ្វើការចូលរួម ចាប់ពីពេលនេះ ឬ ក៏ទៅអនាគត ។

**គំរោងសមាហរណកម្ម ថ្នាក់ស្រុក**

អាជ្ញាធរស្រុក ធ្វើការប្រជុំរៀបចំផែនការជារៀងរាល់ឆ្នាំ ដែលអោយឈ្មោះថា ជា ការប្រជុំសមាហរណកម្ម ។ ការប្រជុំនេះគឺដើម្បី ធ្វើការរួមបញ្ចូលគំរោងផែនការ អភិវឌ្ឍន៍ឃុំ ជាមួយគំរោងផែនការនៃមន្ទីខេត្ត និង អង្គការក្រៅរដ្ឋាភិបាលនានា ។ នេះគឺជាផ្តល់ឱកាស អោយ ឃុំនានា ធ្វើការស្វែងយល់ពីមន្ទីខេត្ត និង អង្គការមិនមែនរដ្ឋាភិបាលនានា អំពីសេវាអ្វី ដែលពួកគេមានបំណងផ្តល់នៅក្នុងឆ្នាំជាបន្តបន្ទាប់ខាងមុខ ដូច្នេះហើយ ដែល គំរោងឃុំមិនមានការជាន់គ្នាជាមួយអ្វី ដែលធ្លាប់បានលើកគំរោងផែនការរួចហើយ ដោយអ្នកផ្សេង ១ ទៀត ។ ហើយគឺជាការផ្តល់ឱកាសចំពោះ គ្រប់ថ្នាក់ដឹកនាំទាំងអស់ ធ្វើការពិភាក្សា នូវគំរោងផែនការ របស់ពួកគេ និងធានាថាមានការសមហេតុផល និង មានការសមស្របក្នុងការពង្រីកការវិនិយោគ ចូលមកក្នុងស្រុក ។

លទ្ធផលនៃការប្រជុំនេះដោយមានការយកចិត្តទុកដាក់ពីមន្ទីខេត្តនិងអង្គការមិនមែនរដ្ឋាភិបាលនានា ធ្វើការផ្តល់នូវសេវាពិតប្រាកដ នៅក្នុងឃុំ នៅក្នុងឆ្នាំ បន្តបន្ទាប់ ។

គំរោងផែនការសមាហរណកម្មថ្នាក់ស្រុកគឺជាផ្នែកមួយ នៃកម្មវិធីសិលា ដែលគ្រប់ អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ត្រូវបានលើកទឹកចិត្តយ៉ាងសកម្មក្នុងការចូលរួម ។

**គំរោងផែនការអភិវឌ្ឍន៍ឃុំ :**

គំរោងផែនការអភិវឌ្ឍន៍ឃុំ គឺជាគំរោងផែនការបីឆ្នាំ ដែលវាត្រូវបានពិនិត្យ និងកែសំរួលជារៀងរាល់ឆ្នាំប៉ុន្តែ ប្រពន្ធ័នៃការប្រមូលពត៌មាន បង្កើតឡើងជារៀងរាល់បីឆ្នាំ ម្តង ។ ដោយធ្លាប់ មានករណី ដែល អង្គការក្រៅរដ្ឋាភិបាល ធ្វើការអនុវត្តន៍គំរោង ដោយមានការចុះបញ្ជី នៅក្នុងគំរោងផែនការឃុំ និងថែមទាំងការចូលរួមចំណែក របស់ អង្គការក្រៅរដ្ឋាភិបាល ដែលកំពុងត្រូវបានប្រើប្រាស់ដោយការ រួមបញ្ចូលជាមួយធនធាននានា នៅក្នុងឃុំដើម្បី ធ្វើការបំពេញទៅតាមគំរោងផែនការ ។ ហើយធ្លាប់មានផងដែរ នូវករណី ដែល អង្គការក្រៅរដ្ឋាភិបាលមានការ ទទួលខុសត្រូវ ចំពោះ ការសំរបសំរួលនៅ ក្នុងដំណើរការរៀបចំផែនការមូលដ្ឋាន នៅក្នុងឃុំ ជាមួយការ បន្ថែម តួនាទីបុគ្គលិករបស់ អង្គការក្រៅរដ្ឋាភិបាល ដែលទូទៅត្រូវបានធ្វើឡើងដោយ មន្ត្រីថ្នាក់ស្រុក( ត្រូវបានគេស្គាល់ថាជា អ្នកសំរបសំរួលថ្នាក់ស្រុក) ។

ដោយឡែកមានការតវ៉ាអំពីសមាជិកខ្លះនៃ គណៈកម្មការអភិវឌ្ឍន៍ភូមិ (CDC) ដោយសារ អ្នកសំរបសំរួលថ្នាក់ ស្រុក ពេលខ្លះ បានធ្វើការងារទាំងអស់ជំនួសពួកគេ ជា ជាងចំណាយពេលវេលា ធ្វើការបង្ហាត់បង្រៀនពួកគេអោយ ចេះធ្វើការ ។ ប្រសិនបើ អង្គការក្រៅរដ្ឋាភិបាល អាចធ្វើការកែសំរួល នូវ សិទ្ធិ នៃការធ្វើទំនាក់ទំនងជាមួយ មន្ត្រីថ្នាក់ឃុំ និង អ្នកសំរបសំរួល ពួកគេប្រហែលជាអាចជួយបាននៅពេលដែលមានករណីនេះកើតឡើង ។

នៅក្នុងករណីដែល ការប្រជុំសមាហរណកម្ម និង គំរោងផែនការឃុំ ដោយមានឧទាហរណ៍រួចជាស្រេចនៃ ការធ្វើការសហការ របស់អង្គកាមិនមែនរដ្ឋាភិបាល ដែល អង្គការក្រៅរដ្ឋាភិបាល នានាអាចរៀនបានអំពីពួកគេ ។ ពីរផ្នែកផ្សេង១ទៀតដែលអង្គការមិនមែនរដ្ឋាភិបាលអាចមានតួនាទីយ៉ាងសំខាន់ក្នុងការចាត់ទុកការចូលរួម ជាមួយ គឺផ្នែកឯកជន និងផ្នែកផ្សេង១ទៀត។ ខ្ញុំមិនបានដឹងអំពីគំរូ ដែលមានការពាក់ពន្ធ័របស់អង្គការមិនមែនរដ្ឋាភិបាល នៃប្រភេទនេះ ។

**ការធ្វើការសហប្រតិបត្តិការជាមួយ ផ្នែកឯកជន និងការអនុវត្តន៍គំរោងនៅក្នុងកម្មវិធីសិក្សា**

ស្ទើរតែគ្រប់ករណីទាំងអស់គំរោងដំណើរការផែនការមូលដ្ឋានត្រូវបានអនុវត្តន៍ដោយ អ្នកម៉ៅការបន្ត ។ ទ្រឹស្តីដែល ស្ថិតនៅពីខាងក្រោយ គឺថាវាមានកាចាប់អារម្មណ៍ ដោយឡែកពីគ្នាដោយមនុស្សផ្សេង១ គ្នា ។ ឧទាហរណ៍ គណៈកម្មការអភិវឌ្ឍន៍ភូមិ និងអ្នកភូមិខ្លួនឯង សាងសង់សាលារៀន ប៉ុន្តែនៅពេលបញ្ចប់ការសាងសង់ពួកគេដឹងថា គំបូលគឺមានគុណភាពមិនសូវល្អ ពួកគេមានការស្ទាក់ស្ទើរក្នុងការធ្វើឡើងវិញ នូវការងារផ្ទាល់របស់ពួកគេ ។ម្យ៉ាងវិញទៀត ប្រសិនបើ មានអ្នកម៉ៅការបន្ត អ្នកភូមិ និងមន្ត្រីនៅក្នុងឃុំ បាន កំពុងតាមដានទៅលើការងារ នៃអ្នកម៉ៅការបន្ត ពួកគេប្រហែលជាធ្វើការទាមទារ អោយអ្នកម៉ៅការបន្ត ធ្វើការរុះរើគំបូលហើយធ្វើវាអោយល្អ ឡើងវិញ ។

នៅក្នុងប្រទេសខ្លះនៅលើពិភពលោកជានិច្ចកាលតែងតែមានឱកាសសំរាប់ធ្វើការពុករលួយ នៅពេលដែលថវិការរដ្ឋត្រូវបានប្រើប្រាស់សំរាប់ជួលអ្នកម៉ៅការឯកជនបន្ត។ ដោយមានការយល់ដឹងអំពីបញ្ហានេះ តើកម្មវិធីសិលាប្រឹងប្រែងរបៀបម៉េចដើម្បីប្រឆាំងជាមួយអំពើពុករលួយទាំងនេះ តើអ្នកម៉ៅការបន្ត និងមន្ត្រីនានាធ្វើយ៉ាងដូចម្តេចដើម្បីព្យាយាមគេចវេសពីច្បាប់ដើម្បីធ្វើការពុករលួយអង្គការមិនមែនរដ្ឋាភិបាលអាចទទួលបាន នូវទស្សនៈសំរាប់ធានាថាថវិការរដ្ឋត្រូវបានប្រើប្រាស់បានយ៉ាងប្រសើរ។

ប្រព័ន្ធនៃកិច្ចសន្យាបានផ្តល់ឱកាសបន្ថែមទៀតនៅក្នុងផ្នែកឯកជន។គំរោងកម្មវិធីសិលាជាច្រើនមិនតំរូវអោយមានកោសលវិច័យបច្ចេកទេសកំរិតខ្ពស់ទេ(ឧទាហរណ៍ ការសាងសង់អណ្តូងស្នប់,ផ្លូវសំរាប់បង្ហូរទឹក) ដោយវាប្រហែលជាអង្គការមិនមែនរដ្ឋាភិបាលអាចជួយដល់ប្រជាជនក្រីក្រក្នុងការបង្កើតឡើង នូវក្រុមការងារផ្ទាល់ខ្លួនរបស់ពួកគេដើម្បីធ្វើការអភិវឌ្ឍន៍ដល់មូលដ្ឋាន។

អ្នកម៉ៅការបន្តត្រូវបានជ្រើសរើសដោយឆ្លងកាត់ការដេញថ្លៃជាសាធារណៈនៅក្នុងឃុំ ។ដោយការសិក្សាអំពីដំណើរការនេះ អង្គការក្រៅរដ្ឋាភិបាលអាចស្វែងរកឃើញ នូវមធ្យោបាយដើម្បីជួយអោយដំណើរការនេះមានប្រសិទ្ធិភាពក្នុងការធានាបាន នូវការសំរេចលទ្ធផលដ៏ល្អបំផុត ។ លក្ខណៈស្រដៀងគ្នានេះដែរ អ្នកម៉ៅការបន្តទាំងអស់ត្រូវតែចុះឈ្មោះដេញថ្លៃជាមួយអាជ្ញាធរខេត្ត (នៅក្នុងប្រទេសហ្វីលីពីន ឧទាហរណ៍ជានិច្ចជាកាលតែងតែមានអង្គការក្រៅរដ្ឋាភិបាលមានវត្តមាន នៅក្នុងគណៈកម្មការដែលទទួលខុសត្រូវក្នុងការយល់ព្រមផ្តល់ទៅអោយអ្នកម៉ៅការបន្ត)

អាជ្ញាធរខេត្តត្រូវបានតំរូវអោយធ្វើការសិក្សាផងដែរលើតំលៃទីផ្សារ ដែលត្រូវប្រើប្រាស់ដោយគំរោងកម្មវិធីសិលាហើយដែលអាចអោយពួកគេធ្វើការតាមដានតំលៃដែលត្រូវបានគិតតំលៃដោយអ្នកម៉ៅការបន្ត ហើយចំពោះបញ្ហានេះដែរជាមធ្យោបាយសំរាប់ការពារនូវអំពើពុករលួយ ។ដោយមានការស្វែងយល់អំពីការសិក្សារបៀបនេះជាច្រើនដែលនឹងជួយអាជ្ញាធរខេត្តក្នុងការដឹកនាំពួកគេ និងអាចជាមធ្យោបាយផ្សេងៗទៀតដែលអង្គការមិនមែនរដ្ឋាភិបាលអាចជួយដល់កម្មវិធីសិលា។

**ការចូលរួមរបស់ប្រជាជននៅក្នុងកម្មវិធីសិលា**

ការសន្មត់ដ៏សំខាន់នៃការកែទំរង់វិមជ្ឈការគឺថារដ្ឋាការមូលដ្ឋានមានការជិតស្និទ្ធជាមួយប្រជាជនជាងអាជ្ញាធរខេត្ត ឬ រដ្ឋាភិបាលជាតិ ។ ទោះជាយ៉ាងណាការកំណត់នេះវាមិនទាន់មានលក្ខណៈពិតជានិច្ចជាកាលនោះទេប្រសិនបើប្រជាជន នៅក្នុងឃុំមិនស្គាល់អ្នកណាដែលស្ថិត នៅក្នុងគណៈកម្មការអភិវឌ្ឍន៍ភូមិរបស់ពួកគេ (ឬក៏ទៅអនាគតអ្នកណាដែលស្ថិត នៅក្នុងក្រុមប្រឹក្សាឃុំរបស់ពួកគេ) និងប្រសិនបើពួកគេមិនបានដឹងថាមានមូលនិធិសំរាប់ការ

